ទម្រង់ទី២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាខេត្តកំពង់ឆ្នាំង**
លេខ ៨១០ សរណ

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៦

អភិបាលនៃគណៈអភិបាលខេត្ត **កំពង់ឆ្នាំង** នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៦ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ ២០១៦ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់ សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំសង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ... ។ល ។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ... ។ល ។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្តូងស្នប់ ... ។ល ។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទង នឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច ។អ្នកទទួលការទាំងឡាយណាដែលត្រូវបានរក ឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតសុំគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ ។

អាស្រ័យហេតុនេះបើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការសូមរួសរាន់មកដាក់ពាក្យសុំចុះ ឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការនិងវិនិយោគនៃសាលាខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ ថ្ងៃទី ១៦ ខែ តុលា **ឆ្នាំ២០១៥ វេលាម៉ោង១៦និង៣០នាទី** ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យ សុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការ និងវិនិយោគសាលាខេត្តដោយឥតបង់ថ្លៃ តាមអាសយដ្ឋានអាគារ ផអព (អតីតអាគារគ.ប្រ )ក្នុងសាលាខេត្តកំពង់ឆ្នាំង ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប ។

អភិបាលខេត្ត

ឈួរ ច័ន្ទឿន